សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខ: ០០២២/១៥ ស.អ.ក

# ប្រកាស
# ស្តីអំពី
## ការបង្កើតគណៈកម្មាធិការ ទទួលបន្ទុកលើការងារសម្របសម្រួលឥណទានជាមួយធនាគារ
(Finance and Banking solution Executive Committee)

## ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

- បានឃើញអនុក្រឹត្យស្តីពីការទទួលស្គាល់នៃការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា លេខ២២៨ អនក្រ.បក ចុះថ្ងៃទី ៨ សីហា ឆ្នាំ ២០១៤ ដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាតកាលពីថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា

## សម្រេច

**ប្រការ១.**

បង្កើតគណៈកម្មាធិការ ទទួលបន្ទុកការកែទំរង់ឲ្យមានការងារសម្របសម្រួលឥណទានជាមួយធនាគារ (Finance and Banking Solution Executive Committee) ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១.លោក សុខ ពុទ្ធិវុធ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា | ប្រធាន |
| ២. លោក អ៊ិត វិជិត ទីប្រឹក្សាជាន់ខ្ពស់របស់ សហព័ន្ធស្រូវអង្ករកម្ពុជា | អនុប្រធាន |
| ៣. ឧកញ៉ា ហ៊ិន ឡាក់ អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា | សមាជិក |
| ៤. ឧកញ៉ា ភូ ពុយ ប្រធានក្រុមហ៊ុន បៃតង និង ធនាគារស្រូវ | សមាជិក |
| ៥. ឧកញ៉ា ប្រាយ សុន ប្រធាន ក្រុមហ៊ុន Capital Food Investment | សមាជិក |
| ៦. លោក វ៉ាន់ វិចិត្រ ទីប្រឹក្សាជាន់ខ្ពស់របស់សហព័ន្ធស្រូវអង្ករកម្ពុជា | សមាជិក |
| ៧. លោក លឹម យ៉ាង៉េត ប្រធានក្រុមហ៊ុន White Gold | សមាជិក |
| ៨. លោក Dith Sochal, ធនាគារ ANZ Royal Bank | សមាជិក |
| ៩. តំណាង ធនាគារ Canadia Bank | សមាជិក |
| ១០. តំណាង ធនាគារ ACLEDA BANK | សមាជិក |
| ១១. តំណាង ធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២. លោក លន់ យ៉េង អគ្គលេខាធិការ សហព័ន្ធស្រូវអង្ករកម្ពុជា | លេខាធិការ |

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការ នៅក្នុងក្របខ័ណ្ឌដែលមានចែង នៅក្នុង ផែនការសកម្មភាព ដែលបានអនុម័តដោយ ក្រុមប្រឹក្សាភិបាលតាមការងារដូចខាងក្រោម៖

- ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាល ចរចារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ធនាគារអភិវឌ្ឍន៍ជនបទ ធនាគារពាណិជ្ជ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្នុងការស្វែងរកយន្តការដោះស្រាយលើមធ្យោបាយផ្តល់ឥណទានដែលមានការប្រាក់ទាបជាងមុន ងាយស្រួល និង លក្ខណៈសម្បទាន
  ជាងមុន ។
- សិក្សាស្វែងរកប្រភពឥណទានដែលមានការប្រាក់ទាប រៀបចំនូវយុទ្ធសាស្ត្រ និងគំរូឥណទាន (Financing Model) ដែលសមស្របសម្រាប់ជាជម្រើសល្អប្រសើរមួយក្នុងការផ្តល់ឥណទានដល់ប្រជាកសិករ រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករកម្ពុជា។
- គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ជាទៀតទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា ។ ចំពោះករណី ការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាត្តិសំរេចជាមុន។
- ក្នុងករណីចំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និង ទីប្រឹក្សាសំរាប់គណៈកម្មាធិការនេះ។

**ប្រការ៣.**

ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និងសាម៉ីខ្លួនត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានី ភ្នំពេញ ថ្ងៃទី១៨ ខែ មីនា ឆ្នាំ២០១៥

**ប្រធាន**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

ចំលងជូន

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- ធនាគារអភិវឌ្ឍន៍ជនបទ
- គំរោងពាណិជ្ជកម្មស្រូវនៅកម្ពុជា របស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ដូចប្រការ ៣
- ឯកសារ កាលប្បវត្តិ